00221498

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

Extraordinary Chambers in the Courts of Cambodia

Chambres Extraordinaires au sein des Tribunaux Cambodgiens

C 22/I/69

អង្គបុរេជំនុំជម្រះ

PRE-TRIAL CHAMBER

CHAMBRE PRELIMINAIRE

សំណុំរឿងព្រហ្មទណ្ឌលេខ: ០០២/១៩-០៩-២០០៧-អវតក-កសចស (អបជ០៣)

| | |
|---|---|
| ចំពោះមុខ: | ចៅក្រម ប្រាក់ គឹមសាន, ប្រធាន |
| | ចៅក្រម Rowan DOWNING |
| | ចៅក្រម ន័យ ថុល |
| | ចៅក្រម Katinka LAHUIS |
| | ចៅក្រម ហួត វុទ្ធី |
| កាលបរិច្ឆេទ: | ២៩ សីហា ២០០៨ |

---

**សាធារណៈ**

**សេចក្តីបង្គាប់ស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ ដោយខ្លួនឯង**

---

**ការិយាល័យសហព្រះរាជអាជ្ញា**

ជា លាង

Robert PETIT

យ៉ែត ចរិយា

William SMITH

គាន់ សេណារ៉ុង

Anees AHMED

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**

ហុង គឹមសួន

ឡោ ជុនធី

នី ចាន់ឌី

គង់ ពិសី

Silke Studzinsky

យុង ផានិត

**ជនត្រូវចោទ**

អៀង សារី

**សហមេធាវីការពារក្តី**

អាង ឧត្តម

Michael G. KARNAVAS

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 29 / Augt / 2008
ម៉ោង (Time/Heure): 10:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 29 / Augt / 2008
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

PRE-TRIAL CHAMBER E.C.C.C. C.E.T.C. CHAMBRE PRELIMINAIRE

១. **អង្គបុរេជំនុំជម្រះ** នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា "អ.វ.ត.ក" យោងលើ "សេចក្តីសម្រេចរបស់ខ្លួនស្តីពីពាក្យសុំពិចារណាសារជាថ្មី លើសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង" ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ ("សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី")[១] ដែលនៅក្នុងនោះបានលើកឡើងថា នឹងមានចេញសេចក្តីសម្រេចមួយចំពោះសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង។

២. អង្គបុរេជំនុំជម្រះរំលឹកថា បន្ទាប់ពីដើមបណ្តឹងរដ្ឋប្បវេណី **សេខ ច័ន្ទធារី** បានដាក់ "ពាក្យសុំពិចារណាសារជាថ្មីស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណី ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះ" និងបន្ទាប់ពីទទួលបានលិខិតរបស់សហចៅក្រមស៊ើបអង្កេត ក្នុងនាមដើមបណ្តឹងរដ្ឋប្បវេណី ដែលមិនមានមេធាវីតំណាងចំនួនបីរូប នៅក្នុងសំណុំរឿងលេខ ០០១ អង្គបុរេជំនុំជម្រះបានទទួលស្គាល់ផលវិបាកដែលអាចកើតមានឡើងចំពោះដើមបណ្តឹងរដ្ឋប្បវេណីដែលមិនទាន់មានមេធាវីតំណាង នៅពេលមានការចេញសេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី។ ដូច្នេះ អង្គបុរេជំនុំជម្រះបានបើកលទ្ធភាពឱ្យជនត្រូវចោទដទៃៗទៀត និងដើមបណ្តឹងរដ្ឋប្បវេណីទាំងនេះ (ដើមបណ្តឹងរដ្ឋប្បវេណីសំខាន់) ដាក់សេចក្តីសន្និដ្ឋានរបស់ខ្លួន។[២]

៣. ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងចំនួនបីរូបនៅក្នុងសំណុំរឿងលេខ ០០១ បានទទួលសេចក្តីសន្និដ្ឋានតបរួមគ្នា។[៣] តាងនាមឱ្យជនត្រូវចោទ អៀង សារី ឬជនត្រូវចោទដទៃទៀត មិនមានសេចក្តីសន្និដ្ឋានផ្សេងទៀតបានទទួលឡើយ។ សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណី ត្រូវបានសង្ខេបនៅក្នុងសេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី។[៤]

៤. អង្គបុរេជំនុំជម្រះពិចារណាឃើញថា វាជាការចាំបាច់ក្នុងការចេញសេចក្តីបង្គាប់បន្ថែម ដើម្បីដោះស្រាយការព្រួយបារម្ភ ស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ដែលដើមបណ្តឹងរដ្ឋប្បវេណីមិនមានមេធាវីតំណាងបានលើកឡើង។

---

[១] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មីស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០០៨ C/22/I/៦៨។

[២] សេចក្តីបង្គាប់បន្ថែមស្តីពីពាក្យសុំពិចារណាសារជាថ្មីស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០០៨ C22/I/59។

[៣] សេចក្តីសន្និដ្ឋានរបស់ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងចំពោះពាក្យសុំពិចារណាសារជាថ្មីស្តីពីសិទ្ធិរបស់ដើមបណ្តឹងរដ្ឋប្បវេណីក្នុងការថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះដោយខ្លួនឯង ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៨ C22/I/63។

[៤] សេចក្តីសម្រេចលើពាក្យសុំពិចារណាសារជាថ្មី វាក្យខណ្ឌទី ២២។

៥. អង្គបុរេជំនុំជម្រះបានលើកឡើងនៅពេលមុនថា ភាគីមានជំហរ និងមានផលប្រយោជន៍ខុសៗគ្នានៅក្នុងដំណាក់កាលក្តីព្រហ្មទណ្ឌ។[៥] ចំពោះដើមបណ្តឹងរដ្ឋប្បវេណី ករណីនេះឆ្លុះបញ្ចាំងនៅក្នុងវិធាន ២៣(១) នៃវិធានផ្ទៃក្នុង ដែលចែងអំពីគោលបំណងនៃបណ្តឹងរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខ អ.វ.ត.ក គឺ (ក) ការចូលរួមនៅក្នុងដំណាក់កាលនីតិវិធីដើម្បីគាំទ្រដល់ការិយាល័យសហព្រះរាជអាជ្ញា និង (ខ) ទាមទារសំណង។ ដើមបណ្តឹងរដ្ឋប្បវេណី ទោះបីមាន ឬគ្មានមេធាវីតំណាង មានលទ្ធភាពផ្តល់ភស្តុតាងដោយខ្លួនឯងនៅពេលធ្វើការគាំទ្រដល់ការិយាល័យសហព្រះរាជអាជ្ញា។ លក្ខណៈនៃបណ្តឹងឧទ្ធរណ៍នៅចំពោះមុខអង្គបុរេជំនុំជម្រះគឺថា ជាទូទៅ បណ្តឹងឧទ្ធរណ៍ទាំងនេះពាក់ព័ន្ធនឹងអង្គច្បាប់ និងអង្គហេតុដែលមាននៅក្នុងសំណុំរឿង។

៦. វិធាន ៧៧(៤)នៃវិធានផ្ទៃក្នុងចែងថា "សហព្រះរាជអាជ្ញា និងមេធាវីរបស់ភាគី អាចពិនិត្យសំណុំរឿងរហូតដល់ថ្ងៃសវនាការ។" ដូចគ្នានេះដែរ មាត្រា ២៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាចែងថា "អគ្គព្រះរាជអាជ្ញានៃសាលាឧទ្ធរណ៍ និងមេធាវី អាចពិនិត្យសំណុំរឿងរហូតដល់ពេលជំនុំជម្រះ។"

៧. ដោយសារមានតែមេធាវីរបស់ភាគីប៉ុណ្ណោះ ដែលអាចពិនិត្យអង្គហេតុនៅក្នុងសំណុំរឿង និងដោយសារនៅក្នុងរឿងក្តីស្ទើរតែទាំងអស់ ដើមបណ្តឹងរដ្ឋប្បវេណីមិនបានទទួលការបណ្តុះបណ្តាលផ្នែកច្បាប់ មេធាវីដែលបានដាក់សេចក្តីសន្និដ្ឋាន គឺជាបុគ្គលដែលអាចផ្តល់ជាជំនួយពាក់ព័ន្ធ ជូនតុលាការនៅក្នុងបញ្ហាទាំងនេះបាន។ យោងតាមគោលការណ៍ជំនុំជម្រះដោយយុត្តិធម៌ អង្គបុរេជំនុំជម្រះបានចេញសម្រេចកាលពីលើកមុន នៅក្នុងសេចក្តីសម្រេចរបស់ខ្លួនស្តីពី ការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសវនាការបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី ២០ ខែមីនា ឆ្នាំ២០០៨ ("សេចក្តីសម្រេចស្តីពីការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី") ដោយលើកឡើងថា ដើមបណ្តឹងរដ្ឋប្បវេណីគួរដាក់សេចក្តីសន្និដ្ឋាន ដើម្បីអាចឱ្យជនត្រូវចោទឆ្លើយតបលើបញ្ហាដែលបានលើកឡើង។[៦]

៨. យុត្តិសាស្ត្រថ្មីមួយគាំទ្រសម្អាងហេតុរបស់អង្គបុរេជំនុំជម្រះ នៅក្នុងសេចក្តីសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណី ហើយយុត្តិសាស្ត្រថ្មីនេះលើកឡើងថា ផលប្រយោជន៍របស់ជនរងគ្រោះក្នុងការចូលរួមនៅក្នុងដំណាក់កាលមុនអង្គសេចក្តី កើតចេញពីសិទ្ធិចំបងចំនួនពីគឺ សិទ្ធិស្វែងរកការពិត និងសិទ្ធិស្វែងរកយុត្តិ-

[៥] សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្ហំ ដែលមេធាវីដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើងនៅក្នុងសវនាការលើបណ្តឹងឧទ្ធរណ៍របស់លោក អៀង សារី ដែលប្តឹងជំទាស់នឹងដីកាសម្រេចឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០៨ C22/I/46 ("សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្ហំ") វាក្យខណ្ឌទី ៣។

[៦] សេចក្តីសម្រេចលើការចូលរួមរបស់ដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងបណ្តឹងឧទ្ធរណ៍ចំពោះការឃុំខ្លួនបណ្តោះអាសន្ន ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៨ C11/53 វាក្យខណ្ឌទី ៤៣។

ធម៌។[៧] បញ្ហាទាំងនេះគឺជាការព្រួយបារម្ភចំបង ដែលពាក់ព័ន្ធនឹងការអនុវត្តឆន្ទានុសិទ្ធិរបស់អង្គជំនុំជម្រះ។ សិទ្ធិនីតិវិធីអាចត្រូវបានគេកម្រិត ប្រសិនបើវាចាំបាច់ក្នុងការធានាដល់ផលប្រយោជន៍ផ្សេងទៀតដែលមានភាពចម្រូងចម្រាស នៅពេលយើងអនុវត្តគោលការណ៍ភាពសមាមាត្រ។[៨] យើងគួរកត់សម្គាល់ថា នៅក្នុងកាលៈទេសៈមួយចំនួន តុលាការព្រហ្មទណ្ឌអន្តរជាតិបានផ្តល់សិទ្ធិយ៉ាងទូលំទូលាយដល់មេធាវីតំណាងរបស់ជនរងគ្រោះ ជាជាងជនរងគ្រោះ ដែលសិទ្ធិយ៉ាងទំលំទូលាយនោះមានដូចជា សិទ្ធិពិនិត្យឯកសារសម្ងាត់ និងសិទ្ធិចូលរួមក្នុងសវនាការអសាធារណៈ។[៩]

៩. អង្គបុរេជំនុំជម្រះទទួលបានថា ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ស្ថិតក្នុងជំហរពិសេសមួយ ហើយអាចមានមេធាវីតំណាងដែលមិនមែនតាមការជ្រើសរើសរបស់ខ្លួន។ ប៉ុន្តែ ពួកគេអាចមានមេធាវីតំណាង ដោយសារបុព្វហេតុថវិកា។

១០. អង្គបុរេជំនុំជម្រះបានទទួលស្គាល់ហើយថា ដោយសារផលវិបាកដែលអាចកើតចេញពីសេចក្តីសម្រេចគឺថា ដើមបណ្តឹងរដ្ឋប្បវេណីអាចនឹងមានមានលទ្ធភាពទាមទារសំណងនៅក្នុងដំណាក់កាលជំនុំជម្រះ។ ផលប្រយោជន៍របស់ដើមបណ្តឹងរដ្ឋប្បវេណី មិនមានភាពខុសគ្នាពីផលប្រយោជន៍របស់សហព្រះរាជអាជ្ញា។[១០] ដោយទទួលស្គាល់អំពីសិទ្ធិស្វែងរកការពិត និងសិទ្ធិស្វែងរកយុត្តិធម៌ នៅក្នុងកាលៈទេសៈបែបនេះ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងដោយស្របច្បាប់ អាចត្រូវបានអនុញ្ញាតឱ្យថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯង។

១១. អង្គបុរេជំនុំជម្រះយល់ឃើញថា ដើម្បីធានាឱ្យមានតុល្យភាពរវាងសិទ្ធិរបស់ភាគីទាំងអស់ ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងដោយស្របច្បាប់ ដែលបានទាមទារសិទ្ធិថ្លែងប្រាស្រ័យជូនតុលាការដោយខ្លួនឯងនៅក្នុងសវនាការដែលបានរៀបចំធ្វើឡើង គួរធ្វើសំណើជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការពន្យល់អំពីខ្លឹមសារ និងភាពជាប់ទាក់ទងនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលបានលើកឡើង។

---

[៧] *រដ្ឋអាជ្ញា ទល់នឹង Katanga* "សេចក្តីសម្រេចលើការកំណត់សិទ្ធិនីតិវិធី ដែលភ្ជាប់ទៅនឹងឋានៈនីតិវិធីរបស់ជនរងគ្រោះនៅក្នុងដំណាក់កាលមុនអង្គសេចក្តី នៅក្នុងរឿងក្តី" លេខ ICC-01/04/-01/07-474 ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ("សេចក្តីសម្រេច ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨")។

[៨] សេចក្តីសម្រេច ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ វាក្យខណ្ឌទី ១៤៨។

[៩] *រដ្ឋអាជ្ញា ទល់នឹង Katanga* "សេចក្តីសម្រេចលើលក្ខខណ្ឌកម្រិតនៃការកំណត់សិទ្ធិនីតិវិធី របស់ជនរងគ្រោះដែលស្គាល់អត្តសញ្ញាណ" លេខ ICC-01/04-01/07-537 ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨ ("សេចក្តីសម្រេច ចុះថ្ងៃទី៣០ ខែឧសភា ឆ្នាំ២០០៨")។

[១០] សេចក្តីសម្រេចលើបញ្ហាបន្ទាន់បង្ខំ វាក្យខណ្ឌទី ៥។



PRE-TRIAL CHAMBER * E.C.C.C. * C.E.T.C. * CHAMBRE PRÉLIMINAIRE

**ដូច្នេះ អង្គបុរេជំនុំជម្រះបង្គាប់:**

(១) ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាងដោយស្របច្បាប់ អាចត្រូវបានអនុញ្ញាតឱ្យថ្លែងប្រាស្រ័យជូនអង្គជំនុំជម្រះដោយខ្លួនឯង នៅពេលផលប្រយោជន៍របស់ខ្លួនមានភាពខុសគ្នាពីផលប្រយោជន៍របស់ព្រះរាជអាជ្ញា។

(២) ដើមបណ្តឹងរដ្ឋប្បវេណីដែលមិនមានមេធាវីតំណាង ដែលបានទាមទារសិទ្ធិថ្លែងប្រាស្រ័យជូនអង្គបុរេជំនុំជម្រះដោយខ្លួនឯងនៅក្នុងសវនាការដែលបានរៀបចំធ្វើឡើង អាចធ្វើសំណើជាលាយលក្ខណ៍អក្សរ ដើម្បីធ្វើការពន្យល់អំពីខ្លឹមសារ និងភាពជាប់ទាក់ទងនឹងសេចក្តីសន្និដ្ឋានរបស់ខ្លួន ដែលបានលើកឡើង យ៉ាងហោចណាស់ឱ្យបានដប់ថ្ងៃ(១០) មុនថ្ងៃសវនាការ។

ភ្នំពេញ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០០៨

**ប្រធានអង្គបុរេជំនុំជម្រះ**

អង្គបុរេជំនុំជម្រះ * PRE-TRIAL CHAMBER * CHAMBRE PRÉLIMINAIRE * E.C.C.C. * C.E.T.C.

**ប្រាក់ គឹមសាន**